# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៨៩

## ស្តីពី

## ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូប

## នៃព្រះរាជាណាចក្រកម្ពុជា

☆☆☆☆☆

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

# ត្រាស់បង្គាប់

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់ឈ្មោះសត្វ និង រុក្ខជាតិ ដែលមានអត្ថិភាព និង សារប្រយោជន៍ពិសេស សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញនូវមរតកធម្មជាតិដ៏មានតម្លៃ និង លើកតម្កើងនូវមោទនភាពជាតិ ។

**មាត្រា ២.-**

សត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា មានឈ្មោះទៅតាមប្រភេទដូចខាងក្រោម :

១- ប្រភេទសត្វចតុប្បាទ : សត្វគោព្រៃ
២- ប្រភេទបក្សី : សត្វក្រយ៉ង
៣- ប្រភេទឧរង្គសត្វ : អណ្តើកសរសៃ (អណ្តើកហ្លួង)
៤- ប្រភេទមច្ឆា : ត្រីគល់រាំង
៥- ប្រភេទរុក្ខជាតិ : ដើមត្នោត
៦- ប្រភេទផ្កា : ផ្ការំដួល
៧- ប្រភេទផ្លែឈើ : ផ្លែចេកពងមាន់

រូបភាព និង លក្ខណៈវិនិច្ឆ័យនៃសត្វ និង រុក្ខជាតិនីមួយៗ ដូចចែងខាងលើ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ទី២ ទី៣ ទី៤ ទី៥ និង ទី៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

សត្វ និង រុក្ខជាតិ ដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវមានវិធានការថែរក្សាការពារ អភិរក្សឱ្យមាននិរន្តរភាព និង ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

**មាត្រា ៤.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

៣៣០.០៥០៣.[illegible]
លេខ ១៧៤.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០០៥
[illegible]អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

3/4

## <u>ឧបសម្ព័ន្ធ ទី១</u>

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/២៤៩ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥
## ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ១- គោព្រៃ (*Bos sauveli*) ជាសត្វមានុញ្ញភាពនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះ **គោព្រៃ** ជាន័យដើម និង ន័យត្រង់នៃភាសាជាតិខ្មែរតែម្តង ហើយត្រូវបានសត្វវិទូអន្តរជាតិទទួលស្គាល់ និង ដាក់នាមដូចៗគ្នា ទោះជាភាសាអង់គ្លេស អេស្ប៉ាញ និង បារាំង គឺប្រើពាក្យតែមួយ **"Kouprey"**។ វាមានឈ្មោះវិទ្យាសាស្ត្រ " *Bos sauveli* " មានប្រវែងដងខ្លួនពី ២,១-២,៣ ម៉ែត្រ មានកម្ពស់ពី ១,៧-១,៩ ម៉ែត្រ និង ទម្ងន់ពី ៧០០-៩០០ គីឡូក្រាម។ គោព្រៃមានរូបរាងស្រដៀងនឹងទន្សោង មានប៉ូវវែងធ្លាក់ចុះដល់ជង្គង់ និង ហៀរស្ទើរតែដល់ដីចំពោះគោឈ្មោល ។ ស្នែងគោព្រៃឈ្មោល និង ញី មានលក្ខណៈប្លែកគ្នា ដោយស្នែងឈ្មោលធំជាង ដុះចេញកោងទៅមុខ និង ងើបឡើងលើ ព្រមទាំងមានព្រុយចុងស្នែង។ ស្នែងញីដុះមកខាងមុខរាងងើបបន្តិច ហើយគួចរមួលឡើងលើ។ ចាប់ពីជើងក្រោមជង្គង់ចុះមក មានពណ៌ស ឬ ប្រផេះ និង ប្រផេះចាស់នៅពេលមានអាយុច្រើន ។ កាលពីសម័យមុនសង្គ្រាម គោព្រៃត្រូវហាមបរបាញ់តាមរយៈប្រកាសលេខ ១៩១ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៦០។ ក្រោយរបប **ប៉ុល ពត** គោព្រៃក៏ត្រូវហាមបរបាញ់ម្តងទៀតតាមរយៈប្រកាសលេខ ៣៥៩ កសក.ប្រក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ គោព្រៃត្រូវហាមឃាត់មិនឱ្យធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយបានចុះក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES និង អនុសញ្ញា Convention on Migratory Species ។ ពិភពលោកបានចាត់ទុកគោព្រៃជាប្រភេទសត្វ **ជិតផុតពូជបំផុត** (Critical Endangered) ដោយបានចុះក្នុងបញ្ជីសៀវភៅក្រហម IUCN។ ក្នុងទសវត្សឆ្នាំ ៦០ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ និង ប្រកាសថា៖ គោព្រៃជានិមិត្តរូបនៃមរតកធម្មជាតិកម្ពុជា។ គោព្រៃក៏ត្រូវចារិកទុកនៅក្នុងបទចម្រៀងប្រជាប្រិយរបស់ខ្មែរតាំងពីយូរយារណាស់មកហើយ ជាពិសេសបទចម្រៀងដែលមានលក្ខណៈរៀបរាប់អំពីធម្មជាតិ ប្រដូចភាពសុខសាន្តនៃការរស់នៅរវាងមនុស្ស សត្វ និង ធម្មជាតិ គឺតែមួយ ។ គោព្រៃជាថនិកសត្វស្លូតរស់នៅជាហ្វូង១ អាចឃើញមានទៅលាយជាមួយហ្វូងទន្សោង ខ្ទីង ឬ ប្រើស។ ជាសត្វវៀងវៃ រហ័សរហួន ឆាប់ភ្ញាក់ផ្អើលជាងប្រភេទសត្វក្នុងត្រកូលគោសាមិះដូចគ្នា ពូកែស្រង់ក្លិន និង គេចវេសចេញពីមនុស្ស ។ មានកម្លាំងខ្លាំង ពូកែធន់នឹងកំដៅថ្ងៃ អត់ធន់នឹងចំណីអាហារដែលមានគុណភាពទាប និង ធន់នឹងជំងឺគោរូត ។
~~~~~

# <u>ឧបសម្ព័ន្ធ ទី២</u>

## នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥
## ស្ដីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

**២- ត្រយ៉ង** (*Pseudibis gigantea*) **ជាបក្សីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា**



ឈ្មោះជាភាសាជាតិ "ត្រយ៉ង ឬ ក្ងោយក្ស ឬ ឪលើក" ។ វាមានឈ្មោះវិទ្យាសាស្ត្រ "***Pseudibis gigantea***" និង ជាភាសាអង់គ្លេស គឺ "**Giant Ibis**"។ វាមានពណ៌សម្បុរប្រផេះក្រម៉ៅ ជើងពណ៌ក្រហមព្រលែត ជំពុះរាងកោងខុបចុះ និង ប្រវែងដងខ្លួន ១០៤ ស.ម ។ ប្រភេទនេះត្រូវការពារដោយប្រកាសលេខ ៣៥៩ កសក.ប្រក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ពិភពលោកក៏បានចាត់ទុកត្រយ៉ងជាប្រភេទ **ជិតផុតពូជបំផុត** (**Critical Endangered**) ដោយបានចុះក្នុងបញ្ជីសៀវភៅក្រហម **IUCN** ដូចគ្នានឹងគោព្រៃដែរ។ ត្រយ៉ងជាប្រភេទសត្វស្លាបដែលកាលពីដើមឡើយមានរាយប៉ាយទូទាំងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែបច្ចុប្បន្ននេះ មាននៅតែក្នុងភូមិភាគខាងជើង និង ឦសាន្តនៃប្រទេសកម្ពុជាប៉ុណ្ណោះ ។ សត្វត្រយ៉ងមានចារឹកក្នុងបទចំរៀងប្រជាប្រិយ និង រឿងនិទានបុរាណខ្មែរ ។ ប្រជារាស្ត្រមានជំនឿថា: ជាសត្វមានភាពវាងវៃ កាលបើមានការបរបាញ់ពុំបានសម្រេចនៅកន្លែងណាមួយហើយ វានឹងមិនត្រឡប់មកទីនោះវិញជាលើកទី២ ឡើយ។ គេមានជំនឿប្រើប្រាស់ឈាមរបស់វាសម្រាប់ព្យាបាលជំងឺគ្រុនចាញ់នៅតាមតំបន់ដាច់ស្រយាល។ ជាប្រភេទសត្វមានប្រជាប្រិយភាព ប្រជាជនមាននិស្ស័យស្រឡាញ់ចូលចិត្តជាពិសេសសម្រែកទាបភ្លឺរបស់វា ដែលជិតជាប់ក្នុងក្រអៅបេះដូងរបស់ប្រជាកសិករខ្មែរក្នុងអត្ថន័យនៃការឆ្លើយឆ្លងសេចក្ដីស្នេហាក៏ដូចជាការរំលឹកពេលវេលាត្រូវចាកចេញទៅធ្វើស្រែចំការផងដែរ ។ ចំណីរបស់វាគឺ សត្វឥតឆ្អឹងកងដែលរស់នៅក្នុងភក់ ដូចជា: ខ្យង ជន្លេន ក្ដាម ។ល។ វាចូលចិត្តរស់នៅក្នុងព្រៃរបោះស្ងួតមានតំបន់ដីសើមច្រើន (ត្រពាំង បឹង ទន្លេ) ។ វាមានដំណើរយឺតៗរកចំណីលើដី និង ទំលើដើមឈើ ដើម្បីសម្រាក និង គេចពួនពីសត្រូវ។ ជាប្រភេទសត្វទើបតែរកឃើញជាថ្មីឡើងវិញនៅកម្ពុជាបន្ទាប់ពីពិភពលោកបានអះអាងថាផុតពូជហើយនោះ ។ ចំនួនរកឃើញថ្មីៗ នៅខេត្តព្រះវិហារ គឺមិនតិចជាង ១០០ ក្បាលឡើយ ដែលជារបាយមួយច្រើនជាងគេក្នុងពិភពលោក។ ប្រទេសកម្ពុជា ជាប្រទេសទីមួយ ដែលបានផ្ដល់រូបថតនៃប្រភេទត្រយ៉ងនេះក្នុងធម្មជាតិមុនគេលើពិភពលោក។ ឥឡូវរូបភាពសត្វនេះត្រូវផ្សព្វផ្សាយទូទាំងពិភពលោកដោយទស្សនាវដ្ដី National Geographic Magazine នៃសហរដ្ឋអាមេរិក។ យើងបានចេញអនុក្រឹត្យបង្កើតតំបន់ព្រៃអភិរក្សធនធានសេនេទិច និង សត្វព្រៃ "ខេត្តព្រះវិហារ" ក៏ជាមូលហេតុនៃការអភិរក្សសត្វត្រយ៉ងនេះជាចម្បងដែរ ។ វាជាប្រភេទសត្វជិតផុតពូជបំផុត ដែលអង្គការអភិរក្សពិភពលោក និង អង្គការក្រៅរដ្ឋាភិបាលនានាកំពុងមានចំណាប់អារម្មណ៍ជួយផ្ដល់ជំនួយការពារថែរក្សាប្រភេទសត្វនេះឱ្យខាងតែបាន ម្យ៉ាងទៀតដោយវាមានសោភ័ណភាព និង រូបរាងស្រស់ស្អាត ជាពិសេសទើបតែរកឃើញឡើងវិញថ្មីៗនេះផងនោះ វាជាប្រភពទាក់ទាញទេសចរណ៍ដ៏សំខាន់មួយ ។
~~~~~

## ឧបសម្ព័ន្ធ ទី៣

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/២៤៩ ចុះថ្ងៃទី...២១... ខែ...មីនា.... ឆ្នាំ ២០០៥ ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

**១- អណ្តើកហ្លួង (*Batagur baska*) ជានិមិត្តរូបសត្វនៃព្រះរាជាណាចក្រកម្ពុជា**



ឈ្មោះជាភាសាជាតិ "អណ្តើកសរសៃ ឬ អណ្តើកហ្លួង" ។ វាមានឈ្មោះវិទ្យាសាស្ត្រ " *Batagur baska* " និង ជាភាសាអង់គ្លេស គឺ " Royal Turtle"។ វាមានភ្នែកពណ៌ស និង ច្រមុះបះឡើង ស្នូករបស់វាមានប្រវែងរហូតដល់ ៦០ ស.ម មានផ្ទៃពណ៌ប្រផេះ ឬ ខ្មៅទាំងអស់ ។ ម្រាមជើងមុខធំមានស្បែកភ្ជាប់គ្នាដូចបាតជើងទា មានក្រញ៉ាំតែបួន គឺ ខុសប្លែកពីអណ្តើកផ្សេងទៀត ដែលមានក្រញ៉ាំប្រាំ។ អណ្តើកនេះត្រូវហាមឃាត់មិនឱ្យធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយបានចុះក្នុងឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES ។ ពិភពលោកបានចាត់ទុកអណ្តើកនេះជាប្រភេទសត្វ **កំពុងទទួលការគំរាមកំហែងជាសកល** (Globally Threaten) ដោយបានចុះក្នុងបញ្ជីសៀវភៅក្រហម IUCN ។ កាលពីបុរាណ អណ្តើកនេះ មានប្រវត្តិការពារដោយព្រះរាជក្រឹត្យ និង បានចាត់ទុកជាសម្បត្តិរបស់រាជវង្សនៅកម្ពុជាយើង ។ ពងអណ្តើកនេះ ជារឿយៗប្រមូលបានពីខែ មករា ដល់ខែ មីនា ដែលនៅពេលនោះគេយកទៅថ្វាយតែចំពោះរាជវង្សសោយប៉ុណ្ណោះ ដូចនេះទើបប្រជារាស្ត្រឱ្យឈ្មោះថា **អណ្តើកហ្លួង** រហូតដល់សព្វថ្ងៃនេះ ។ ក្រោយមកប្រជារាស្ត្រឱ្យតែចាប់បានអណ្តើកនេះ តែងតែយកមកតុបតែងលាបប្រេង ម្សៅនិមន្តព្រះសង្ឃសូត្រធម៌បួងសួងសុំសេចក្តីសុខ ហើយដោះលែងទៅវិញ ។ វាចូលចិត្តរស់នៅតាមតំបន់ពាមសមុទ្រ មានព្រែកតូចៗ ដែលមានព្រៃកោងកាង ឬ មានរុក្ខជាតិផ្សេងទៀតដុះតាមមាត់ទឹក ។ ជាប្រភេទសត្វស៊ីអាហារគ្រប់យ៉ាង មានស្លឹកឈើ ពន្លករុក្ខជាតិ ផ្លែកោងកាង និង សត្វតូចៗផ្សេងទៀត ។ ក្នុងអំឡុងទសវត្សឆ្នាំ៨០ និង ៩០ គេជឿថាអណ្តើកនេះបានផុតពូជពីកម្ពុជាទៅហើយ ទើបតែនៅឆ្នាំ ១៩៩៩ បានរកឃើញនៅស្រុកស្រែអំបិល ខេត្តកោះកុង ហើយនៅឆ្នាំ ២០០២ កន្លងទៅនេះ នាយកដ្ឋានជលផលសហការជាមួយអង្គការ WCS ភ្ញាស់បាន ៣២កូន ហើយបានលែងទៅក្នុងធម្មជាតិវិញ ។ វាជាប្រភេទជិតផុតពូជ ដែលអង្គការអភិរក្សពិភពលោក និង អង្គការក្រៅរដ្ឋាភិបាលនានាកំពុងមានចំណាប់អារម្មណ៍ ជួយផ្តល់ជំនួយការពារថែរក្សាប្រភេទសត្វនេះឱ្យខាងតែបាន និង ម្យ៉ាងទៀតគួបផ្សំនឹងទីជម្រកព្រៃកោងកាងដ៏ស្រស់ស្អាត វាជាប្រភពទាក់ទាញទេសចរណ៍មួយដ៏គួរឱ្យចាប់អារម្មណ៍ ។
~~~~~

## ឧបសម្ព័ន្ធ ទី៤

### នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/២៤៩ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥ ស្ដីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

**៤- ត្រីគល់រាំង (*Catlocarpio siamensis*) ជាមច្ឆជាតិនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា**



ឈ្មោះជាភាសាជាតិ "ត្រីកាហោ ឬ ត្រីក្បាលឡាន ឬត្រីគល់រាំង "។ វាមានឈ្មោះវិទ្យាសាស្ត្រ " Catlocarpio siamensis " និង ឈ្មោះជាភាសាអង់គ្លេស " Giant Mekong Barb"។ វាជាប្រភេទត្រីមានទំហំធំជាងគេនៅកម្ពុជា ។ វាអាចមានទម្ងន់ពី ១៥០-៣០០ គីឡូក្រាម និង ប្រវែងដងខ្លួនពី ២-៣ ម៉ែត្រ ។ ជាប្រភេទត្រីមានស្រកាធំៗគ្របដណ្ដប់លើផ្ទៃដងខ្លួនទាំងមូល លើកលែងតែផ្នែកក្បាល និង ព្រុយប៉ុណ្ណោះ។ ពណ៌សម្បុរលើដងខ្លួនទាំងមូល មើលឃើញថាមានពីរពណ៌ដាច់ដោយឡែកពីគ្នា ស្រកាដែលនៅលើខ្សែឆ្នូតចំហៀងខ្លួនមានពណ៌ក្រម៉ៅថ្នា ។ ដោយឡែក ស្រកាឋិតនៅក្រោមខ្សែឆ្នូតចំហៀងខ្លួនមានពណ៌ប្រាក់ ។ ប្រភេទត្រីនេះ ត្រូវការពារដោយក្រឹត្យច្បាប់លេខ ៣៣ ក្រ.ច ស្ដីពីការគ្រប់គ្រងវិស័យជលផលក្នុងជំពូក ២ មាត្រា ១៨ ។ បច្ចុប្បន្ននេះនាយកដ្ឋានជលផលបានណែនាំ និង លើកទឹកចិត្តដល់ស្ថានីយ៍ភ្ញាស់ និង បង្កាត់ពូជត្រីនានា ឱ្យធ្វើការសិក្សាស្រាវជ្រាវភ្ញាស់ និង បង្កាត់ប្រភេទពូជត្រីនេះ ដើម្បីលែងចូលក្នុងដែនទឹកធម្មជាតិ និង ធ្វើវារីវប្បកម្ម ។ ចាប់តាំងពីឆ្នាំ ២០០០ មក នាយកដ្ឋានជលផលបានសហការជាមួយគម្រោងគ្រប់គ្រងនេសាទទឹកសាបកម្ពុជា បានធ្វើការលែងត្រីគល់រាំងដែលនេសាទបានដោយជាយ ដោយដាក់សញ្ញាសម្គាល់ ដើម្បីតាមដានចរាចរ និង ការលូតលាស់របស់វា។ ត្រីគល់រាំងជាប្រភេទត្រីទឹកសាបមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ។ គេឃើញមានរស់នៅតាមដងទន្លេមេគង្គ ជាពិសេសសំបូរជាងគេនៅបឹងទន្លេសាប ។ រូបភាពប្រភេទត្រីនេះ ត្រូវបុព្វបុរសខ្មែរយើងឆ្លាក់ជារូបចម្លាក់ដាក់លើប្រាង្គប្រាសាទអង្គរវត្ត ។ គេនិយមយកស្រកាត្រីគល់រាំងមកធ្វើជាសីទាត់ក្នុងល្បែងប្រជាប្រិយខ្មែរយើង។ បើប្រៀបធៀបទៅនឹងប្រភេទត្រីក្នុងស្រុកផ្សេងទៀត ត្រីគល់រាំងមានមាឌធំជាងគេនៅក្នុងប្រទេសកម្ពុជា ហើយស្ទួតពុំដេញចាប់ប្រភេទត្រីផ្សេងទៀតជាអាហារឡើយ។ សាច់របស់វាមានរស់ជាតិឆ្ងាញ់ ប្រជាជននិយមចូលចិត្តបរិភោគ ។ បច្ចុប្បន្ននេះ យើងបាននិងកំពុងជំរុញដល់ស្ថានីយ៍ភ្ញាស់បង្កាត់នានា ឱ្យព្យាយាមស្រាវជ្រាវភ្ញាស់ផលិតពូជត្រីនេះ ដើម្បីផ្សព្វផ្សាយឱ្យប្រជាកសិករយកទៅចិញ្ចឹម ព្រោះវាងាយស៊ីចំណីធម្មជាតិ ឆាប់ធំ និង អាចរក្សាពូជរបស់វាបាន ។ ទន្ទឹមនឹងនេះដែរ យើងបានបង្កើតតំបន់ការពារអន្លង់ត្រីជាច្រើននៅតាមទន្លេមេគង្គ ដើម្បីអភិរក្សពូជត្រីដ៏ជិតផុតពូជនេះ ។ វាជាប្រភេទត្រីមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ សម្រាប់ការផ្សព្វផ្សាយឱ្យប្រជាកសិករចិញ្ចឹម ព្រោះវាងាយស៊ីចំណីធម្មជាតិ និង ឆាប់ធំ និង ជាប្រភេទជិតផុតពូជ ដែលអង្គការអភិរក្សពិភពលោក និង អង្គការក្រៅរដ្ឋាភិបាលនានា កំពុងមានចំណាប់អារម្មណ៍ជួយផ្ដល់ជំនួយការពារថែរក្សាប្រភេទត្រីនេះឱ្យខាងតែបាន ។
~~~~~

## ឧបសម្ព័ន្ធ ទី៥

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៤៨ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥

## ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ៥- ដើមត្នោត (Borassus flabellifer) ជារុក្ខជាតិនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ "ត្នោត" ។ វាមានឈ្មោះវិទ្យាសាស្ត្រ " ***Borassus flabellifer*** " និង ជាភាសាអង់គ្លេស គឺ " **Sugar Palm** " ។ ត្នោតជាប្រភេទរុក្ខជាតិស្ថិតក្នុងតាលព្រឹក្សខ្ពស់ មានដើមទោល គល់ធំ ដុះត្រង់ឡើងលើ កម្ពស់ពី ១០-២៥ ម ឬសវាមានលក្ខណៈជាឬសយោង និង គ្មានឬសកែវ ។ តួដើមត្នោតមានភាពគគ្រើមពណ៌ក្រម៉ៅ អង្កត់ផ្ចិតពី ២០-៦០ ស.ម ដោយប្រែប្រួលទៅតាមគុណភាពដី ។ កន្សែងស្លឹកមានរាងដូចផ្ចិត ប្រមូលផ្តុំគ្នានៅផ្នែកចុងកំពូលនៃដើម ។ ធាងត្នោតរលោងក្រាស់មានពណ៌លឿងបៃតងពេលនៅខ្ចី និង លឿងត្នោតពេលមានអាយុចាស់ ព្រមទាំងមានបន្លានៅគែមទាំងសងខាងសណ្ឋានដូចជាធ្មេញរណារ ។ ត្នោតញី និង ឈ្មោលមានលក្ខណៈខុសប្លែកគ្នាតាមការសម្គាល់លើផ្ការបស់វា ។ ផ្កាត្នោតឈ្មោលមានរាងមូលទ្រវែង ទំហំពី ២-៤ ស.ម ប្រវែងពី ៣០-៥០ ស.ម ។ រីឯផ្កាត្នោតញីមានសណ្ឋានជាពកមូល១ប្រវែងពី ៥០-៧០ ស.ម ដែលអាចផ្តល់ផ្លែបានចំនួនពី ២០-៥០គ្រាប់ ។ ផ្លែត្នោតមានរាងមូលពណ៌ត្នោតក្រម៉ៅនៅភាគខាងក្រោម និង ពណ៌បៃតងនៅភាគខាងលើនៃផ្លែ ហើយប្រែពណ៌ទៅជាលឿងទុំក្រម៉ៅពេលវាចាស់-ទុំ ។ ផ្លែត្នោតមានអង្កត់ផ្ចិត ប្រមាណពី ១៣-២០ ស.ម ដែលប្រែប្រួលទៅតាមគុណភាពដី ការកៀបយកទឹក និង អាយុកាលរបស់ដើម ។ ត្នោតជារុក្ខជាតិប្រជាប្រិយ៍តំណាងឱ្យសង្គមខ្មែរ ដែលមានវត្តមាន និង ផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងដល់ប្រជាជាតិខ្មែរតាំងពីសម័យកំណកំណើតនគរខ្មែរ និង ជាអត្តសញ្ញាណដែលប្រជាជនខ្មែរសម្គាល់នូវទេសភាពទឹកដីរបស់ខ្លួន តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន ស្របនិងពាក្យស្លោកថា " **ដើមត្នោតជាជម្រកផ្ទះខ្មែរ** " ។ កាលពីឆ្នាំ ២០០៣ កន្លងទៅនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាពិនិត្យ មានវិធានការទប់ស្កាត់កុំមានការបំផ្លាញទ្រព្យធម្មជាតិដូចជាព្រៃឈើ និង ដើមត្នោតជាដើម ដែលបន្ទាប់មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានចេញនូវសារាចរណែនាំលេខ ៤៨១ សរណន.កសក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និង ធ្វើអាជីវកម្មដើមត្នោត ។ ក្នុងសង្គមខ្មែរ ដើមត្នោតមានសារៈសំខាន់ច្រើនយ៉ាងណាស់ដូចជា: ឬសត្នោត និង ផ្កាត្នោតឈ្មោលជាឱសថបុរាណសំរាប់កែរោគគ្រុនចាញ់ កាមរោគ ឬ រោគស្ពឹកចុងដៃចុងជើង ។ ដើមត្នោតអាចយកមកប្រើប្រាស់នៅក្នុងសំណង់លំនៅស្ថាន ក្រោលសត្វ ទូក ឬ សំណង់ផ្សេងទៀត ។ បច្ចុប្បន្នដើមត្នោតបានកែច្នៃជាផលិតផលសិប្បកម្មដ៏មានតម្លៃក្នុងទីផ្សារ ។ ស្លឹកសម្រាប់ប្រក់ និង ធ្វើជញ្ជាំងផ្ទះ ត្បាញកន្ទេល ទូក ស្នុក និង ពេលខ្លះអាចប្រើប្រាស់ស្លឹកត្នោតសម្រាប់ចារ ឬ សរសេរជំនួសស្លឹកទ្រាំង បានទៀតផង ។ ផ្លែត្នោត និង ទឹកត្នោតមានឱជារសឈ្ងុយឆ្ងាញ់ពិសារជាទីពេញនិយមនៃសង្គមខ្មែរ ។ ការផលិតស្ករត្នោតដោយរំងាស់ពីទឹកត្នោត គឺជាប្រពៃណីរបស់ប្រជារាស្ត្រខ្មែរតាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ។
~~~~~

# ឧបសម្ព័ន្ធ ទី៦

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥
## ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ៦- ផ្ការំដួល (*Mitrella mesnyi* ) ជាផ្កានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ "រំដួល "។ វាមានឈ្មោះវិទ្យាសាស្ត្រ " **Mitrella mesnyi**"។ រំដួលជាប្រភេទរុក្ខជាតិមានកម្ពស់ពី ៨-១២ម និង មានអង្កត់ផ្ចិតពី ២០-៣០ស.ម ។ ដើមមានសំបកពណ៌ត្នោត-លឿង ស្លឹកជាប្រភេទស្លឹកទោលដុះឆ្លាស់ គ្មានខ្នាយស្លឹក ទម្រង់បន្ទះស្លឹករាងទ្រវែងមានទំហំ ២-៤ x ៦-១០ ស.ម ។ ផ្ការំដួលមានពណ៌លឿង-ស មានក្លិនក្រអូបផ្សាយបានឆ្ងាយ ចោលក្លិននៅពេលរសៀល និង ពេលព្រលប់ ។ ផ្លែជាចង្កោម ពេលទុំមានពណ៌ក្រហមក្រម៉ៅអាចបរិភោគបាន ។ រំដួលមានដុះលូតលាស់ដោយធម្មជាតិស្ទើរគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ហើយត្រូវបានប្រជាជនយើងនិយមយកមកដាំលំអតាមគេហដ្ឋាន និងសួនសាធារណៈ។ ដោយផ្ការំដួលមានក្លិនក្រអូបរបៀបនេះ ខ្មែរយើងពីបុរាណកាលនិយមប្រើប្រាស់វាជាគ្រឿងផ្សំផលិតជាក្រមួនលាបមាត់របស់នារី ។ ដើមរំដួលក៏អាចកែច្នៃប្រើប្រាស់ជាគ្រឿងសំណង់បន្ទាប់បន្សំ និង ប្រើជាអុសសំរាប់ដុត ។ នៅរដូវផ្លែរំដួលទុំ ប្រជាជនដែលរស់នៅក្បែរព្រៃតែងតែបេះផ្លែរំដួលយកមកលក់ដោះស្រាយជីវភាព ។ ដោយសារផ្ការំដួលមានក្លិនដ៏ក្រអូបជាទីទាក់ទាញអារម្មណ៍របស់មហាជនទូទៅ ហេតុនេះបានជានៅក្នុងសង្គមខ្មែរ គេច្រើនប្រដូចនារីខ្មែរទៅនឹងផ្ការំដួលរហូតដល់មានកវីនិពន្ធខ្មែរខ្លះបានបន្សល់ទុកនូវបទចម្រៀងមួយចំនួនដូចជា: **រំដួលក្រចេះ** និង **រំដួលពោធិសាត់** ជាដើម ។

### ៧- ចេកពងមាន់ Banana (*Musa aromatica*) ជាផ្លែឈើនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ "ចេកពងមាន់ "។ វាមានឈ្មោះវិទ្យាសាស្ត្រ "**Musa aromatica**" និង ជាភាសាអង់គ្លេស គឺ " **Chicken Egg Banana**"។ ចេកត្រូវគេនិយមបរិភោគ និង ប្រើប្រាស់ជាទូទៅដោយប្រជាជនកម្ពុជាគ្រប់ជាន់ថ្នាក់ ។ គេអាចបរិភោគផ្លែចេកទុំ ឬ កែច្នៃជាដំណាប់ ចេកបន្ទះ ចេកឆាប ជាដើម ។ ក្រៅពីនេះ ចេកប្រជាជនកម្ពុជានិយមប្រើជាសំណែន ឬ ជំនូនគ្រប់ពិធីផ្សេងៗ ដែលសូម្បីតែសម្រាប់ថ្វាយគោរពបូជាទេវតារាល់ថ្ងៃសីលផងដែរ ។ ក្នុងពាក្យស្លោក " ពេលឈើយកដីរទៅបន់ ពេលជំងឺស្រន់ចេកពងមាន់ក៏ស្តាយ " នោះបញ្ជាក់ថា ចេកត្រូវប្រើប្រាស់ជាទូទៅ ព្រោះមានតម្លៃថោក ហើយផលិតផលនេះមានពោរពេញគ្រប់ទិសទី ។ ចេកពងមាន់ភាគច្រើនត្រូវគេដាំនៅតាមដីសណ្តទន្លេមេគង្គ ជាពិសេសនៅតាមតំបន់កោះដុះថ្មី ។ ចេកគេដាំនៅកម្ពុជា ជាយូរលង់ណាស់មកហើយ ថ្វីត្បិតតែជាដំណាំដែលមានប្រភពពីឥណ្ឌាក៏ដោយ ។ តួយ៉ាងរឿងព្រេងបុរាណខ្មែរ" ចៅស្រទបចេក" ជាភស្តុតាងស្រាប់ ។ ក្រៅពីបានដាំយកផ្លែ ដើម្បីជាប្រភពចំណូលប្រចាំគ្រួសាររបស់កសិករនោះ ដំណាំចេកជាដំណាំប្រើបានច្រើនមុខទៀត ដូចជា: គល់របស់វាជាប្រភពជាតិម្សៅ ( អាមីដុង) ពិសេសក្នុងពេលជួបគ្រោះ ទុរ្ភិក្សម្តងមួយកាល ដើមវាអាចហាន់ជាចំណីជ្រូក គោ ក្របី ។ល។ ធ្វើជាខ្សែចំណងផ្សេងៗ ធ្វើជាបាយសីក្នុងពិធីសែនព្រេននានា ស្លឹកប្រើជាសម្ភារៈវេចខ្ចប់នំចំណី និង ត្រយូងប្រើជាបន្លែស្រស់ ឬ ស្ល ។
~~~~~